# Office Worksite Protocols: Appendix G
# វិធីសា សម្រាប់ កន្លែងការងារការិយាល័យ: ទំព័រ G

វិធីសាស្រ្តនេះ សម្រាប់បំពេញដោយអាជីវកម្មណា ដែលមានកន្លែងការងារការិយ៉ាល័យ។ សេចក្តីតម្រូវខាងក្រោមនេះ សម្រាប់អនុវត្ត រាល់កន្លែងការងារការិយាល័យ។ ការបន្ថែមលក្ខខ័ណ្ឌពីអភិបាល បានកំណត់លើអាជីវកម្មណា ដែលមានមូលដ្ឋានការិយាល័យ ហើយអាជីវកម្ម ត្រូវតែគោរពតាមវិធីសារនេះ ផងដែរ។ វិធីសានេះ ត្រូវតែអនុវត្តបិទ និងផ្សាយមុនពេលប្រតិបត្តិការ នៅក្នុងការិយាល័យ។

សូមកត់សម្គាល់ថា៖ ឯកសារនេះ ត្រូវបានធ្វើឡើងក្នុងពេលបច្ចុប្បន្ន សម្រាប់ជាព័ត៌មានបន្ថែម និងធនធានដែលមាន និងប្រាកដចូលមើល វែបសាយរបស់ឡុងប៊ិច កូវិដ-១៩ www.longbeach.gov/covid19 ជាប្រចាំ សម្រាប់ព័ត៌មានថ្មីៗ អំពីឯកសារនេះ។

**បញ្ជីពិនិត្យមើល មានដូចជា៖**

(1) ច្បាប់នៅកន្លែងធ្វើការងារ និងការអនុវត្ត ដើម្បីការពារសុខភាពបុគ្គលិក
(2) វិធានការ ប្រាកដថា រាងកាយនៅឃ្លាតឆ្ងាយពីគ្នា
(3) វិធានការ ដែលអាចគ្រប់គ្រងការឆ្លងរាលដាល
(4) ទំនាក់ទំនងជាមួយបុគ្គលិក និងសាធារណជន
(5) វិធានការដើម្បីធានា ការទទួលបាននូវសេវាកម្ម ចាំបាច់ប្រកបដោយសមធម៌

អាជីវកម្មទាំងអស់ ត្រូវអនុវត្តវិធានការណ៍ ដែលអាចអនុវត្តបានទាំងអស់ មានរាយបញ្ជីនៅខាងក្រោមនេះ ហើយត្រូវត្រៀមពន្យល់ពីមូលហេតុ វិធានការណ៍ណាមួយ ដែលមិនបានអនុវត្ត និងមិនត្រូវអនុវត្ត។

ឈ្មោះអាជីវកម្ម: ____________________
ទីកន្លែងអាស័យដ្ឋាន៖ ____________________

## A. មាតិការ នៃផែនការសម្រាប់កន្លែងធ្វើការងារ

អ្នកទទួលខុសត្រូវ ក្នុងការអនុវត្តផែនការ។
ការវាយតម្លៃអំពីហានិភ័យ និងវិធានការត្រូវតែអនុវត្ត ដើម្បីការពារការរីករាលដាលនៃមេរោគ។
បណ្តុះបណ្តាល និងទំនាក់ទំនងជាមួយបុគ្គលិក និងតំណាងបុគ្គលិក អំពីផែនការនេះ។
ធ្វើការពិនិត្យមើល សម្រាប់ការប្រព្រឹត្តតាមច្បាប់ និងធ្វើកំណត់ឯកសារ និងកែតម្រូវចំណុចណាដែលខ្វះខាត។
.ធ្វើការស៊ើបអង្កេតករណី កូវិដ-១៩ ជូនដំណឹងទៅដល់ផ្នែកសុខាភិបាលក្នុងមូលដ្ឋាន និងកំណត់អត្តសញ្ញាណ និងបិទផ្តាច់ការមានទំនាក់ទំនងនៅកន្លែងធ្វើការ របស់បុគ្គលិក ដែលមានជម្ងឺ រហូតដល់ពួកគេត្រូវបានធ្វើតេស្ត។

## B. ប្រធានបទ សម្រាប់ការបណ្តុះបណ្តាលបុគ្គលិក

ព័ត៌មានអំពីកូវិដ-១៩ COVID-19 ការពារការរីករាលដាល និងមនុស្សណាដែលងាយរងគ្រោះបំផុត។ ការពិនិត្យដោយខ្លួនឯងនៅផ្ទះ រួមទាំងការស្ទង់កំដៅសីតុណ្ហភាព និង/ឬ ការត្រួតពិនិត្យរោគសញ្ញា ដោយធ្វើតាមគោលការណ៍ណែនាំរបស់ CDC guidelines. ។

**រាយការណ៍អំពីការបំពានច្បាប់**
**សូមទូរស័ព្ទមក (562) 570-2633 ឬ**
**អ៊ីម៉ែល៖ CETASKFORCE@LONGBEACH.GOV**

សារៈសំខាន់នៃការមិនមកធ្វើការ ប្រសិនបើបុគ្គលិកមានអាការៈ ក្អកញឹកញាប់ គ្រុនក្តៅ ពិបាកដកដង្ហើម រងាររញ្ញាក់ ឈឺសាច់ដុំ ឈឺក្បាល ឈឺបំពង់ក បាត់បង់រសជាតិ ឬក្លិនថ្មីៗ ឬប្រសិនបើពួកគេ ឬនរណាម្នាក់ ដែលពួកគេរស់នៅជាមួយ ត្រូវបានគេធ្វើរោគវិនិច្ឆ័យឃើញថាមានជម្ងឺកូវីដ-១៩ នេះ ។

តើពេលណា ត្រូវស្វែងរកការព្យាបាល។

សារៈសំខាន់ នៃការលាងដៃ។

សារៈសំខាន់នៃការឃ្លាតឆ្ងាយពីរាងកាយ ទាំងនៅកន្លែងធ្វើការនិងក្រៅម៉ោងធ្វើការ។

## C. វិធានការត្រួតពិនិត្យបុគ្គល និងការពិនិត្យរកមើលរោគ

ការពិនិត្យរោគសញ្ញា និង/ឬ ការត្រួតពិនិត្យមើលកំដៅសីតុណ្ហភាព។

លើកទឹកចិត្តបុគ្គលិកណា ដែលឈឺ ឬបង្ហាញរោគសញ្ញាកូវីដ-១៩ អោយស្នាក់នៅផ្ទះ។

លើកទឹកចិត្តឱ្យលាងដៃញឹកញាប់ និងប្រើទឹកអនាម័យសំអាតដៃ។

ផ្តល់ស្រោមដៃ ដែលអាចពាក់បោះចោលបាន ដល់កម្មករ ដោយប្រើរបស់សំអាត និងលាងសម្លាប់មេរោគ ប្រសិនបើចាំបាច់។ ពិចារណាថា ស្រោមដៃជាការបន្ថែមជាមួយ នឹងការលាងដៃឱ្យបានញឹកញាប់ នៅពេលលាងសំអាតផ្សេងៗ ដូចជាកិច្ចការដែលបានប៉ះជាទូទៅ ឬធ្វើការពិនិត្យរោគសញ្ញា។

តម្រូវអោយបុគ្គលិក និងកម្មករជាប់កិច្ចសន្យា ដែលមានកាតព្វកិច្ច តម្រូវអោយមានទំនាក់ទំនងជិតស្និទ្ធ ជាមួយបុគ្គលិកផ្សេងទៀត និង/ឬសាធារណជន ត្រូវពាក់ប្រដាប់បិទបាំងមុខ។

សម្គាល់: ការបិទបាំងមុខ គឺមិនគួរប្រើជាវិធានការជំនួសភស្តុតាងផ្សេងៗ ដើម្បីការពារនៃការរីករាលដាលកូវីដ-១៩ ។ ការបិទបាំងមុខគួរតែប្រើបន្ថែមលើវិធានការ ដែលផ្អែកលើភស្តុតាងផ្សេងទៀត (ឧទាហរណ៍៖ ការឃ្លាតឆ្ងាយរាងកាយ អនុវត្តន៍ការលាងដៃញឹកញាប់ ជៀសវាងការប៉ះភ្នែករបស់យើង ច្រមុះ និងមាត់ ដោយមិនប្រើដៃ និងជៀសវាងការនៅក្បែរមនុស្សឈឺ) ។

បិទ ឬបង្កើនចម្ងាយរវាងតុ/កៅអី នៅក្នុងបន្ទប់សម្រាក ឬផ្តល់កន្លែងសម្រាកនៅទីវាល ដើម្បីធានាបាននូវការឃ្លាតរាងកាយឆ្ងាយពីគ្នា។

ប្រាស្រ័យទាក់ទងឱ្យបានញឹកញាប់ ប្រាប់ដល់អតិថិជនថា ពួកគេគួរតែប្រើបាំងមុខ/ពាក់បិទបាំងមុខ។

បន្ទប់សម្រាក បន្ទប់ទឹក និងកន្លែងធម្មតាផ្សេងទៀត កំពុងត្រូវបានសំអាតសម្លាប់មេរោគ ជាញឹកញាប់ ហើយបានស្តុកទុកសំភារៈអនាម័យចាំបាច់ តាមកាលកំណត់។

ការសំអាតសម្លាប់មេរោគ មានប្រសិទ្ធិភាព ប្រឆាំងនឹងកូវីដ-១៩ និង និងមានសម្ភារៈសំរាប់បុគ្គលិកទាំងអស់ នៅតាមទីតាំង៖

ទឹកអនាម័យសំអាតសម្លាប់មេរោគ មានប្រសិទ្ធិភាព ប្រឆាំងនឹងកូវីដ-១៩ និង និងមានសំរាប់បុគ្គលិកទាំងអស់ នៅតាមទីតាំង៖

សាប៊ូ និងទឹក មានសម្រាប់បុគ្គលិកទាំងអស់ នៅតាមទីតាំង៖

## D. វិធីសា សម្រាប់ការសំអាត និងសម្លាប់មេរោគ

អនុវត្តការលាងសម្អាតឱ្យបានហ្មត់ចត់ នៅកន្លែងតំបន់ចរាចរណ៍ខ្ពស់។

សំអាតសម្លាប់មេរោគជាញឹកញាប់ លើផ្ទៃរបស់របរប្រើប្រាស់ជាទូទៅ និងកន្លែងធ្វើការផ្ទាល់ខ្លួន។

សម្អាត និងលាងអនាម័យឧបករណ៍ ដែលបានចែកចាយ រវាងការប្រើប្រាស់នីមួយៗ។

សម្អាតលើផ្ទៃរបស់របរប្រើប្រាស់ ដែលអាចប៉ះបានរវាងការប្តូរវេនគ្នា ជាមួយអ្នកប្រើប្រាស់ ទោះបីជាញឹកញាប់ក៏ដោយ។

ដាក់នៅតាមទីធ្លាដែលចែកចាយប្រើរួមគ្នា ជាមួយផលិតផលអនាម័យត្រឹមត្រូវ រួមទាំងទឹកអនាម័យលាងដៃ និងប្រដាប់ជូតអនាម័យ ហើយធានាថាមានសម្រាប់ប្រើប្រាស់។

ធានាថាកន្លែងដាក់របស់អនាម័យ មានសម្រាប់ប្រតិបត្តិការ និងស្តុកទុកគ្រប់ពេលវេលា។

**រាយការណ៍អំពីការបំពានច្បាប់**
**សូមទូរស័ព្ទមក (562) 570-2633 ឬ**
**អ៊ីម៉ែល៖ CETASKFORCE@LONGBEACH.GOV**

ប្រើផលិតផលណា ត្រូវបានអនុញ្ញាត ឱ្យប្រើប្រឆាំងនឹងកូវីដ-១៩ ក្នុងបញ្ជី ដែលបានអនុម័ត ដោយទីភ្នាក់ងារការពារបរិស្ថាន (EPA) និងធ្វើតាមការណែនាំផលិតផល និងតម្រូវការ Cal / OSHA ។

ផ្តល់ពេលវេលាដល់បុគ្គលិក ដើម្បីហាត់រៀនអនុវត្តធ្វើការសំអាតអនាម័យមុនពេល និងក្រោយពេលប្តូរវេនគ្នា ហើយពិចារណារកក្រុមហ៊ុនទីបី មកជួយសំអាត។

ដំឡើងឧបករណ៍ ដោយមិនបាច់ប្រើដៃ បើអាចធ្វើបាន។

ពិចារណា ធ្វើឱ្យប្រសើរឡើង ដើម្បីកែលម្អ ឬប្រដាប់ច្រោះសំអាតខ្យល់ និងម៉ាស៊ីនខ្យល់។

## E. គោលការណ៍ណែនាំ អំពីរាងកាយ នៅឃ្លាតឆ្ងាយពីគ្នា

អនុវត្តវិធានការបំបែកបុគ្គលិក អោយរាងកាយនៅឆ្ងាយពីគ្នា យ៉ាងតិច ៦ហ្វីត ដោយប្រើវិធានការដូចជា ការរាប់ចំនួនមនុស្ស ឬ តាមការមើលឃើញ (ឧទាហរណ៍ គំនូសនៅលើក្តារ ឥដ្ឋ បង់ស្អិតលាបពណ៌ ឬសញ្ញាណាដែលចង្អុលបង្ហាញ ទីកន្លែងបុគ្គលិកគួរឈរ) ។

ការគិតគូរឡើងវិញ អំពីទំហំការិយាល័យ តូបការិយាល័យ ។ ល។ និងកាត់បន្ថយចំនួនមនុស្ស ចូលរួមសន្និសីទ និងទីកន្លែងប្រជុំ។

កំណត់ចំនួនមនុស្សចូលរួមប្រជុំដោយផ្ទាល់ ប្រសិនបើចាំបាច់ ដើម្បីធានារាងកាយនៅឆ្ងាយពីគ្នា។

ចែកពេលឈប់សម្រាករបស់បុគ្គលិក ដោយអនុលោមតាមច្បាប់ប្រាក់ឈ្នួល និងម៉ោង ប្រសិនបើចាំបាច់។

កែតម្រូវរចនាសម្ព័ន្ធឡើងវិញ ឬបិទតំបន់ប្រើប្រាស់រួមគ្នា និងផ្តល់ជម្រើសកន្លែង ដែលអាចអនុវត្ត រាងកាយនៅឃ្លាតឆ្ងាយពីគ្នា។

កំណត់ចំនួនបុគ្គលជិះក្នុងជណ្តើរយន្ត និងប្រាកដថា ប្រើប្រាស់ប្រដាប់បិទបាំងមុខ។

អនុវត្តធ្វើការងារ នៅពេលដែលអាចធ្វើទៅបាន និងចាំបាច់ ដើម្បីកំណត់ចំនួនបុគ្គលិក នៅកន្លែងការិយាល័យក្នុងពេលតែមួយ ដូចជាការងារតាមអិនធឺណឺត និងកែប្រែកំណត់ថ្ងៃធ្វើការ។

ដាក់សញ្ញានៅច្រកចូលសាធារណៈ ក្នុងកន្លែងនីមួយៗ ដើម្បីជូនដំណឹងដល់បុគ្គលិក និងអតិថិជនទាំងអស់ថា ពួកគេគួរតែ: (i) ចៀសវាងចូលទៅក្នុងកន្លែងនោះ ប្រសិនបើពួកគេ ក្អក ឬក្តៅខ្លួន។ (ii) រក្សាកំរិតចម្ងាយប្រាំមួយហ្វីត ពីមនុស្សមួយ ទៅមួយទៀត។ (iii) កណ្តាស់ និងក្អក ទៅក្នុងក្រណាត់ ឬក្រដាស ឬបើមិនមានទេ ដាក់ទៅក្នុងកែងដៃមួយក៏បានដែរ និង (iv) កុំចាប់ដៃ ឬចូលរួមទំនាក់ទំនងរាងកាយជាមួយអ្វី ដែលមិនចាំបាច់។

ដាក់ផ្លាកប្រកាសក្រដាសចម្លង អំពីពិធីសាស្រ្តនៃការឃ្លាតរាងកាយឆ្ងាយពីគ្នា នៅតាមច្រកចូលសាធារណៈនីមួយៗ ក្នុងទីកន្លែងនោះ។

ហាមឃាត់ប្រជាជនមិនឱ្យផ្តល់ និងបម្រើខ្លួនឯងរបស់របរណាទាក់ទងនឹងអាហារ រួមទាំងអាហារជុំគ្នា ឬបម្រើខ្លួនឯងអាហារថ្ងៃត្រង់ដែលដឹកជញ្ជូន។

**វិធានការបន្ថែមណាមួយ ដែលមិនបានរាប់បញ្ចូលខាងលើ គួរតែ ត្រូវបានចុះបញ្ជីនៅលើទំព័រដាច់ដោយឡែក ដែលអាជីវកម្ម គួរតែភ្ជាប់ជាមួយនឹងឯកសារនេះ។**

**អ្នកអាចទាក់ទងជាមួយមនុស្ស នៅខាងក្រោមនេះ ចំពោះសំណួរឬយោបល់ អំពីវិធីសានេះ៖**

**ឈ្មោះអាជីវកម្ម:** ______________________ **លេខទូរសព្ទ:** ______________________

**កាលបរិច្ឆេទ**
**កែប្រែចុងក្រោយ:** ______________________

**រាយការណ៍អំពីការបំពានច្បាប់**
**សូមទូរស័ព្ទមក (562) 570-2633 ឬ**
**អ៊ីម៉ែល៖ CETASKFORCE@LONGBEACH.GOV**